Fiscal Year
2025
Proposed
Budget

# កិច្ចប្រជុំសុំយោបល់សហគមន៍ រឿងថវិកា

CITY OF
LONG
BEACH



# កិច្ចប្រជុំនេះមានបកប្រែជូន

- សូមបងប្អូនជ្រើសយកការបកប្រែភាសាណាមួយ ទៅតាមការពេញចិត្ត ដើម្បីចូលរួមក្នុងកិច្ចប្រជុំនេះ។
- សេវាបកប្រែផ្ទាល់មាត់នេះ មានជាភាសាអេស្ប៉ាញ ខ្មែរ និងតាហ្កាឡុក
  - អេស្ប៉ាញ
  - ខ្មែរ
  - តាហ្កាឡុក
  - ភាសាសញ្ញា ( ASL )

# កិច្ចប្រជុំសុំយោបល់សហគមន៍រឿងថវិកា

- ម៉ោង 6:00 ល្ងាច – 7:30 ល្ងាច
  - មតិស្វាគមន៍ និងបើកអង្គប្រជុំ
  - មតិអ្នកគ្រប់គ្រងទីក្រុង
  - អំពីដំណើរការរៀបចំថវិកាឆ្នាំសារពើពន្ធ ២០២៥
  - មតិពលរដ្ឋជុំវិញថវិកាក្រុង

# សមាសភាពក្រុមការងារ

## ថំម ម៉ូឌីកា (Tom Modica)

អ្នកគ្រប់គ្រងទីក្រុង

## ជែរ៉ាល់ឌីន អាឡេហូ (Geraldine Alejo)

អ្នកគ្រប់គ្រងថវិកាស្តីទី

## តំណាងនាយកដ្ឋាន

- នាយកដ្ឋានត្រៀមគ្រោះមហន្តរាយ និងទំនាក់ទំនងគ្រាអាសន្ន
- នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍
- នាយកដ្ឋានអគ្គីភ័យ
- នាយកដ្ឋានបណ្ណាល័យ
- នាយកដ្ឋានសុខាភិបាល និងសេវាពលរដ្ឋ
- នាយកដ្ឋានឧទ្យាន កំសាន្ត និងថែរក្សាសត្វសមុទ្រ
- នាយកដ្ឋានប៉ូលិស
- នាយកដ្ឋានសាធារណការ



# មតិអ្នកគ្រប់គ្រងក្រុង

# សមិទ្ធផលថវិកាឆ្នាំសារពើពន្ធ ២០២៤

មានការអភិវឌ្ឍនិងប្រសិទ្ធភាពគួរឲ្យកត់សម្គាល់ ដែលឈានទៅសម្រេចចក្ខុវិស័យយុទ្ធសាស្ត្រទីក្រុងឡុងប៊ិចឆ្នាំ ២០២៣ ដោយបញ្ចូលទឹកប្រាក់ប្រើបានតែម្តងចំនួន ២៧ លានដុល្លារ សម្រាប់ការវិនិយោគសំខាន់ៗ ដោយមិនឲ្យប៉ះពាល់ដល់កង្វះថវិកាក្នុងកញ្ចប់ថវិកាទូទៅ។





បានដាក់ចេញកម្មវិធីអភិវឌ្ឍសម្រាប់ឆ្នាំ ២០២៨ សម្រាប់ផែនការទុនវិនិយោគរយៈពេលសរុប ៥ ឆ្នាំ ដែលមានទឹកប្រាក់ ៧៥៨ លានដុល្លារ យកទៅកែលម្អហេដ្ឋារចនាសម្ព័ន្ធទីក្រុង ត្រៀមទទួលកីឡាអូឡាំពិកឆ្នាំ ២០២៨ និងបន្តកែលម្អ និងពង្រឹងឧទ្យានក្នុងក្រុង ផ្លូវចក្រចូលធំៗ និងតំបន់ទទួលបម្រើភ្ញៀវ។

នៅអាចរក្សាបានថវិកាគ្រាអាសន្នទូទៅ និងប្រាក់បម្រុងសម្រាប់ប្រតិបត្តិការ។





CITY OF LONGBEACH



# ទិដ្ឋភាពថវិកាឆ្នាំសារពើពន្ធ ២០២៥ និងវិធីសាស្ត្រ

# ការព្យាករណ៍ដំណើរនៃថវិកាទូទៅ តាំងពីមានវិបត្តិកូវីដ

| | ឆ្នាំ ២០២០ | ឆ្នាំ ២០២១ | ឆ្នាំ ២០២២ | ឆ្នាំ ២០២៣ បាន់ស្មាន | ឆ្នាំ ២០២៤ អនុម័តរួច |
|---|---|---|---|---|---|
| លទ្ធផលដាច់ឆ្នាំ | ខ្វះ ២១ លានដុល្លារ | លើស ២ លានដុល្លារ | ខ្វះ ១២ លានដុល្លារ | លើស ២១ លានដុល្លារ *នឹងដឹងនៅខែ កុម្ភៈ ឆ្នាំ ២០២៤* | ខ្វះ ៩ លានដុល្លារ *នឹងដឹងនៅខែ កុម្ភៈ ឆ្នាំ ២០២៥* |

Pandemic Hits

LONG BEACH ច្បាប់ស្ដីពីការស្ដារក្រុងឡើងវិញ

ថវិកាកើនឡើងច្រើនតាមរយៈគំនិតថ្មី

LONG BEACH ច្បាប់ស្ដីពីការស្ដារក្រុងឡើងវិញ

# វិធីរៀបចំខ្លួនឲ្យបានល្អ ដើម្បីជោគជ័យទៅអនាគត

- រក្សាទម្លាប់ល្អប្រចាំឆ្នាំ និងមានវិន័យ ដើម្បីចៀសវាងស្ថានការណ៍ខ្វះថវិកាធ្ងន់ធ្ងរ (ឧទាហរណ៍ ចៀសវាងចំណាយលើអ្វីមួយ ដែលពុំមានប្រាក់ប៉ះប៉ូវបង្គ្រប់វិញ)
- ប្រើវិធីសាស្ត្រជាយុទ្ធសាស្ត្រក្នុងការចាយថវិកាសម្រាប់ប្រើប្រាស់បានតែម្តង ក្នុងរយៈពេលខ្លី ប៉ុន្តែមិនមែនជាអ្វីមួយដែលចាត់ទុកថាជាដំណោះស្រាយរយៈពេលវែង
- រកមើលគំនិតថ្មីៗ ដើម្បីពង្រីកប្រាក់ចំណូលសេដ្ឋកិច្ច និងចំណូលបន្ថែម

**គោលនយោបាយហិរញ្ញវត្ថុ**
**គោលនយោបាយហិរញ្ញវត្ថុសរុប ២១**

- ថវិកានឹងមានតុល្យភាព
- ថវិកាមានប្រចាំឆ្នាំ– កាត់បន្ថយការកែប្រែពាក់កណ្តាលឆ្នាំ
- ថ្លៃអ្នកប្រើប្រាស់កំណត់ទៅតាមភាពជាក់ស្តែងនៃថ្លៃសេវា
- ប្រាក់បម្រុងសម្រាប់គ្រាអាសន្ន និងប្រតិបត្តិការនៅរក្សាបាន
- មានការរំពឹងទុកថានឹងមានការកើនឡើងប្រាក់ចំណូល
- សេចក្តីថ្លែងការណ៍អំពីផលប៉ះពាល់ក្នុងឆ្នាំសារពើពន្ធ
- ថវិកាដែលប្រើបានតែម្តង គឺសម្រាប់ប្រើបានតែម្តងនោះឯង
- លែលកទុកបំណុល ៥ភាគរយ
- បំណុលនឹងត្រូវរក្សាឲ្យក្នុងកម្រិតសមស្រប
- ផ្សេងពីនេះមាននៅក្នុងសៀវភៅថវិកា

# ទិដ្ឋភាពថវិកាសារពើពន្ធទូទៅជាបឋម– ការពិនិត្យមើលពីដំបូងៗ

- ទិដ្ឋភាពថវិកានេះ គឺកំពុងឋិតក្នុងដំណាក់កាលដំបូងៗប៉ុណ្ណោះ ដោយត្រូវរង់ចាំការពិនិត្យ និងធ្វើបច្ចុប្បន្នភាពបន្ថែម។ ទិដ្ឋភាពនេះនឹងប្រែប្រួលសម្រាប់ខែ មីនា ឆ្នាំ ២០២៤ ដែលយើងនឹងធ្វើបទបង្ហាញជូនទៅក្រុមប្រឹក្សាក្រុង។
- ជារួម ទិដ្ឋភាពនេះថវិកានេះ ត្រូវបង្ហាញជូនទៅក្រុមប្រឹក្សាក្រុងនៅខែ មីនា។ ដោយសារតែមានការប្រែប្រួលច្រើនក្នុងការអនុម័តថវិកាឆ្នាំសារពើពន្ធ ២០២៤ នេះគ្រាន់តែជាការផ្តល់នូវទិដ្ឋភាពរួមដំបូងៗ ដែលជាផ្នែកមួយនៃថវិកា និងវិធីសាស្ត្រឆ្នាំសារពើពន្ធ ២០២៥។
- ការប្រែប្រួលតាំងពីអនុម័តកញ្ចប់ថវិកាឆ្នាំសារពើពន្ធចុងក្រោយនោះមក គឺថវិកាឆ្នាំសារពើពន្ធ ២០២៤ ត្រូវបានអនុម័តដោយបញ្ចូលផលប៉ះពាល់នៃការកិច្ចព្រមព្រៀងផ្នែកការងារ និងការកាត់បន្ថយចំណូលដែលបានពីប្រេង។
- ដកចេញការប្រើប្រាស់ថវិកាសម្រាប់ប្រើបានតែម្តង ដូចជាថវិកាបានពីច្បាប់ស្តីពីការស្តារក្រុងឡុងប៊ិចឡើងវិញ ដែលសាលាក្រុងមានលទ្ធភាពរក្សាវាទុកបានយូរជាងអ្វីដែលបានគ្រោងទុក និងអាចនៅមានសម្រាប់យកមកប្រើប្រាស់ដោះស្រាយការខ្វះថវិកាក្នុងឆ្នាំសារពើពន្ធ ២០២៥ (សម្រាប់ឆ្នាំសារពើពន្ធសរុប ៤ឆ្នាំ នៃដំណោះស្រាយសម្រាប់តែម្តងនេះ)។

# ទិដ្ឋភាពថវិកាសារពើពន្ធទូទៅជាបឋម– ការពិនិត្យមើលពីដំបូងៗ ( ត )

| អតិរេក( ប្រាក់លើស ) ក្នុងមូលនិធិទូទៅ / (កង្វះថវិកា) គិតជាលានដុល្លារ* | | | | | | |
|---|---|---|---|---|---|---|
| | ព្យាករណ៍ ឆ្នាំសារពើពន្ធ ២០២៥ | ព្យាករណ៍ ឆ្នាំសារពើពន្ធ ២០២៦ | ព្យាករណ៍ ឆ្នាំសារពើពន្ធ ២០២៧ | ព្យាករណ៍ ឆ្នាំសារពើពន្ធ ២០២៨ | ព្យាករណ៍ ឆ្នាំសារពើពន្ធ ២០២៩ | ព្យាករណ៍ ឆ្នាំសារពើពន្ធ ២០៣០ |
| ប្រាក់លើស/(ប្រាក់ខ្វះ) – ប្រចាំឆ្នាំ | (19.6) | (7.5) | (6.9) | (10.3) | (13.2) | (5.0) |
| *ប្រាក់ខ្វះពីឆ្នាំមុន* | (8.8) | - | - | - | - | - |
| *ប្រាក់លើស/(ប្រាក់ខ្វះ) សរុបចូលគ្នា* | **(28.4)** | **(35.9)** | **(42.8)** | **(53.1)** | **(66.3)** | **(71.3)** |

*តួលេខទាំងនេះនឹងប្រែប្រួល/នឹងត្រូវធ្វើបច្ចុប្បន្នភាពជាថ្មី នៅខែ មីនា ឆ្នាំ ២០២៤

# វិធីសាស្ត្រជាបទដ្ឋានដើម្បីដោះស្រាយបញ្ហាខ្វះថវិកា

- ប្រសិទ្ធភាពនៃដំណើរប្រតិបត្តិការ
- ការកាត់បន្ថយសកម្មភាពប្រតិបត្តិការ និងកាត់បន្ថយសេវា
- បង្កើន និងកំណត់ប្រភពចំណូលថ្មីៗ

# កង្វះថវិកាអាចឈានទៅកាត់បន្ថយសេវា

| *ការកាត់បន្ថយសេវាប្រហាក់ប្រហែល (សម្រាប់តែគោលបំណងបង្ហាញប៉ុណ្ណោះ)* | ថ្លៃចំណាយប្រតិបត្តិការ |
|---|---|
| រាល់កម្មវិធីក្មេងជំទង់នៅឧទ្យាន | $265,000 |
| រាល់កម្មវិធីបោះជំរុំនៅឧទ្យាន | $458,000 |
| រាល់កីឡាយុវជន | $613,000 |
| រាល់ការជួសជុលនិងថែទាំឧទ្យាន (ដី ដើមឈើ និងបឹង) | $11,930,000 |
| បណ្ណាល័យបីសាខា | $3,600,000 |
| រាល់ការកាត់តម្រឹមដើមឈើ | $5,100,000 |
| រថយន្តលុបជង្ហុកបីគ្រឿង | $2,200,000 |
| រាល់គណនេយ្យ និងប្រតិបត្តិការថវិកាស្នូល | $5,200,000 |
| ប្រតិបត្តិការរថយន្តពន្លត់អគ្គីភ័យមួយគ្រឿង | $3,400,000 |
| បុគ្គលិកសង្គ្រោះម្នាក់ | $1,700,000 |
| មន្ត្រីប៉ូលិស ៦នាក់ | $1,400,000 |
| **សរុប** | **$35.9** លាន |

# គម្រោងលូតលាស់ឡុងប៊ិច៖ ឱកាសសេដ្ឋកិច្ច សមធម៌ និងភាពធន់នឹងវិបត្តិ

- យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច កំណត់គោលដៅបាញ់ឆ្ពោះទៅរកឧស្សាហកម្មដែលកំពុងលូតលាស់ ដើម្បីបង្កើនការងារក្នុងមូលដ្ឋាន និងប្រាក់ចំណូល។
- ទោះបីពេលនេះជាដំណាក់ដំបូងៗក្ដី ក៏គំនិតផ្ដួចផ្ដើមគម្រោងអភិវឌ្ឍន៍ធំៗ បានជួយជម្រុញមូលដ្ឋានកំណើនសេដ្ឋកិច្ចរបស់ក្រុង និងប្រាក់ចំណូល ដើម្បីរីកចម្រើនក្នុងទិសដៅថ្មី និងប្រកបដោយចីរភាពជាងនេះ ដោយរួមមាន៖
  - ក្រុមហ៊ុនថ្មី និងមានភាពច្នៃប្រឌិត បិតក្នុងក្រុងឡុងប៊ិច (ឧទាហរណ៍ ក្រុមហ៊ុន Aevum និង Jet Zero)
  - នាំមកនូវកម្មវិធីលើកកម្ពស់ឡុងប៊ិច– កម្មវិធីកែលម្អធំបំផុតមួយ ដើម្បីផ្ដល់ជំនួយបច្ចេកទេស និងថវិកាជំនួយខ្នាតតូច ដល់អាជីវកម្មក្នុងមូលដ្ឋាន
  - ជំរុញអាជីវកម្ម និងការលូតលាស់ផ្នែកទេសចរណ៍ តាមរយៈការវិនិយោគនៅមជ្ឈមណ្ឌលសន្និសីទ និងកប៉ាល់ឃ្វីនម៉ារី រួមទាំងសណ្ឋាគារ Hard Rock Hotel
- ផលប៉ះពាល់ក្នុងឆ្នាំសារពើពន្ធ ពីគម្រោងលូតលាស់ឡុងប៊ិច យើងនៅមិនទាន់ដឹងនៅឡើយ។ ប៉ុន្តែផលប្រយោជន៍យើងដឹងហើយ។ ដូច្នេះផលប៉ះពាល់នឹងត្រូវបញ្ចូលនៅក្នុងការព្យាករណ៍នាពេលអនាគត។

# កង្វះថវិកាក្នុងមូលនិធិទូទៅ នឹងមិនអាចដោះស្រាយបានដោយខ្លួនឯង ប៉ុន្តែមានជម្រើស

- ដំណោះស្រាយដោយប្រើថវិកា សម្រាប់ប្រើប្រាស់បានតែមួយដងនោះ គឺមានភាពកំណត់ និងបានតែក្នុងពេលបណ្តោះអាសន្ន
- ការចំណាយនៅតែរំពឹងថានឹងកើនឡើង ជាពិសេសពាក់ព័ន្ធនឹងកិច្ចចរចារឿងប្រាក់ឈ្នួលក្នុងវិស័យការងារ ដែលបានធ្វើរួច។
- មូលដ្ឋាននៃប្រាក់ចំណូលជាប្រព័ន្ធបច្ចុប្បន្ន (មានភាពកំណត់ និងងាយប្រែប្រួល) នឹងត្រូវតែកើនឡើងក្នុងកម្រិតមួយលឿនជាងការកើនឡើងនៃការចំណាយ
- មើលទៅការខ្វះថវិកាទៅអនាគត ទំនងជាមិនអាចដោះស្រាយដោយខ្លួនឯងបាននោះឡើយ បើគ្មានអន្តរាគមន៍ ហើយនឹងត្រូវឲ្យមានការកាត់ ពង្រីកប្រភពរកប្រាក់ចំណូលថ្មី និងបន្ថែម ប្រសិទ្ធភាព ឬប្រើប្រាស់ឲ្យអស់គ្រប់វិធី។



# ការរួសរាន់សុំយោបល់ពីសហគមន៍




- ការរួសរាន់សុំយោបល់សហគមន៍នេះ គឺមានក្នុងផែនការដែលត្រូវធ្វើនៅមុនធ្វើសេចក្តីសម្រេចលើសំណើថវិកា។
- មតិរបស់សហគមន៍នឹងរាយការណ៍ជូនទៅក្រុមប្រឹក្សាក្រុង នៅមុនបញ្ចេញសំណើថវិកាឆ្នាំសារពើពន្ធ ២០២៥ ក្នុងខែ សីហា
- កិច្ចប្រជុំសុំយោបល់សហគមន៍ និងការស្ទង់មតិទូទៅ នឹងត្រូវធ្វើក្នុងខែ មករា៖

| ថ្ងៃ ពុធ<br>ទី ១៧ ខែ មករា<br>ម៉ោង ៦-៧:៣០ ល្ងាច | ថ្ងៃ ចន្ទ<br>ទី ២២ ខែ មករា<br>ម៉ោង ៦-៧:៣០ ល្ងាច | ថ្ងៃ ព្រហស្បតិ៍<br>ទី ២៥ ខែ មករា<br>ម៉ោង ៦-៧:៣០ ល្ងាច | ថ្ងៃ ចន្ទ<br>ទី ៣០ ខែ មករា<br>ម៉ោង ៦-៧:៣០ ល្ងាច | ថ្ងៃ ព្រហស្បតិ៍<br>ទី ៣១ ខែ មករា<br>ម៉ោង ៦-៧:៣០ ល្ងាច |
|---|---|---|---|---|
| Museum of Latin American Art - 628 Alamitos Ave. | Doris Topsy-Elvord Community Center at Houghton Park - 6301 Myrtle Ave. | Cabrillo High School - 2001 Santa Fe Ave. | Recreation Park Community Center - 4900 E 7th St. | Zoom Webinar |

- បងប្អូនអាចរកព័ត៌មានបន្ថែមបាននៅទីនេះ៖ **longbeach.gov/FY25**

# ចុះនឹងមានអ្វីកើតឡើងក្រោយពីនេះ?

- **មករា-កុម្ភៈ៖** បុគ្គលិកបន្តរៀបចំព័ត៌មានថ្មីៗ និងចុងក្រោយអំពីការព្យាករណ៍ថវិកាឆ្នាំសារពើពន្ធ ២០២៥ និងពិនិត្យឡើងវិញការព្យាករណ៍ឆ្នាំផុតពីនេះ
- **មករា៖** កិច្ចប្រជុំសុំយោបល់សហគមន៍
- **កុម្ភៈ៖** របាយការណ៍ដាច់ឆ្នាំសារពើពន្ធ ២០២៣ ដាក់ជូនទៅក្រុមប្រឹក្សាក្រុង
- **មីនា៖** ការព្យាករណ៍ឆ្នាំសារពើពន្ធ ២០២៥ និងឆ្នាំផ្សេងទៀត ដាក់ជូនទៅក្រុមប្រឹក្សាក្រុង



# កិច្ចពិភាក្សាសហគមន៍៖
# ផ្នែកសេវាសំខាន់ៗជាអាទិភាព

# ចក្ខុវិស័យយុទ្ធសាស្ត្រក្រុងឡុងប៊ិចឆ្នាំ ២០៣០

- ចក្ខុវិស័យទូទាំងក្រុង ដែលជាប្រទីពបំភ្លឺផ្លូវដល់ការសម្រេច/គោលនយោបាយទូលំទូលាយ
- ដោយផ្តោតលើសមធម៌ និងភាពធន់នឹងវិបត្តិ
- បញ្ចូលផែនការក្រុង ៣០+ សំណូមពរពីអភិបាលក្រុង ក្រុមប្រឹក្សាក្រុង មន្ត្រីក្រុង គំនិតរបស់សហគមន៍ជាង ២០,០០០
- មានប្រធានបទរួមមានលេចឡើង៖ កែលម្អគុណភាពជីវិតសម្រាប់ពលរដ្ឋទាំងអស់ ដែលរស់នៅក្នុងទីក្រុងឡុងប៊ិច
- កំណត់គោលដៅចម្បងៗ និងយុទ្ធសាស្ត្រសម្រាប់សហគមន៍ និងរៀបចំរដ្ឋាភិបាលក្រុងរបស់យើង ដើម្បីយើងមានលទ្ធភាពឆ្លើយតបបានទៅតាមតម្រូវការជាក់ស្តែងជាមូលដ្ឋានរបស់ពលរដ្ឋសហគមន៍។

# ចក្ខុវិស័យយុទ្ធសាស្ត្រក្រុងឡុងប៊ិចឆ្នាំ ២០៣០

## រៀបចំចេញជា ៨ ផ្នែក៖

- អប់រំ
- ឱកាសសេដ្ឋកិច្ច សមធម៌ និងភាពធន់នឹងវិបត្តិ
- ការគិតគូរផ្នែកឪដីថល និងបច្ចេកវិទ្យា
- លំនៅឋាន និងភាពអនាថា
- ការធ្វើដំណើរ សមធម៌ផ្នែកទីធ្លា និងការគិតគូរឡើងវិញចំពោះសិទ្ធិអាទិភាពរបស់សាធារណជន
- សុវត្ថិភាពសាធារណៈ
- សុខភាព សុខភាពផ្នែកសម្បទា និងសុខុមាលភាព
- និរន្តរភាពផ្នែកអាកាសធាតុ និងបរិស្ថាន

**ព័ត៌មានបន្ថែម៖** www.longbeach.gov/vision2030

# ការចូលរួមក្នុងកិច្ចពិភាក្សាសហគមន៍ថ្ងៃនេះ

- មានប្រធានបទបួន នៅជុំវិញបន្ទប់នេះ ដែលរៀបចំជាសេវា ៨ ផ្នែក ពាក់ព័ន្ធនឹងចក្ខុវិស័យជាយុទ្ធសាស្រ្តក្រុងឡុងប៊ិចឆ្នាំ ២០៣០
  - សូមបោះឆ្នោតរើសយកសេវាដែលសំខាន់ៗបំផុតសម្រាប់បងប្អូន
  - សូមផ្តល់មតិ
  - សូមសួរសំណួរដល់មន្ត្រីសាលាក្រុង
- បងប្អូនអាចដើរមើលប្រធានបទមួយណាក៏បាន ដោយសេរី
  - សូមដើរមើលប្រធានបទទាំងនោះតាមសម្រួល ប៉ុន្តែគួរចំណាយពេលមួយកន្លែងត្រឹម ១០នាទី
  - អ្នកបកប្រែភាសានឹងចាប់ផ្តើមជួយបងប្អូន ទៅតាមភាសាដែលបងប្អូនត្រូវការ

# ផ្នែកសេវាសំខាន់ៗជាអាទិភាព

## Long Beach Budget Priorities

CITY OF LONGBEACH

ENCUESTA DE PRIORIDAD DEL PRESUPUESTO DE LONG BEACH
ការស្ទង់មតិរកចំណុចសំខាន់ៗលើគេសម្រាប់ថវិកាក្រុងឡុងប៊ិច
LONG BEACH BUDGET PRIORITY SURVEY

### Education
Educación
ការអប់រំ
Edukasyon

CITY OF LONGBEACH

### Economic Opportunity, Equity and Resiliency
Oportunidad económica, equidad y resiliencia
ឱកាសសេដ្ឋកិច្ច សមធម៌ និងភាពធន់នឹងវិបត្តិ
Oportunidad pang Ekonomiya, Pagkapantaypantay at Katatagan

CITY OF LONGBEACH

### Housing and Homelessness
Vivienda y personas sin hogar
លំនៅឋាន និងភាពអនាថា
Pabahay at Kawalan ng Bahay

CITY OF LONGBEACH

### Digital Equity, Inclusion & Technology
Inclusión digital y tecnología
សមធម៌ផ្នែកឌីជីថល ការគិតគូរ និងបច្ចេកវិទ្យា
Digital na Pagkakasamasama at Teknolohiya

CITY OF LONGBEACH

### Mobility & Placemaking
Movilidad y creación de entorno urbano
ការធ្វើដំណើរ និងបង្កើតទីធ្លា
Paggalaw at Pagsasalugar

CITY OF LONGBEACH

### Public Safety
Seguridad pública
សុវត្ថិភាពសាធារណៈ
Kaligtasan ng Publiko

CITY OF LONGBEACH

### Health & Wellness
Salud y bienestar
សុខភាព និងសុខុមាលភាព
Kalusugan at Kagalingan

CITY OF LONGBEACH

### Climate & Environmental Sustainability
Clima y sostenibilidad ambiental
និរន្តរភាពអាកាសធាតុ និងបរិស្ថាន
Pagpapanatili ng Klima at Kapaligiran

CITY OF LONGBEACH

ព័ត៌មានបន្ថែម៖ www.longbeach.gov/vision2030

# មតិសហគមន៍ និងកិច្ចពិភាក្សា

- គោលដៅសំខាន់ គឺស្ដាប់មតិរបស់បងប្អូន។ មតិរបស់បងប្អូនមានសារសំខាន់។ យើងខ្ញុំលើកទឹកចិត្តឲ្យបងប្អូន ចែករំលែកមតិ នៅតាមប្រធានបទនីមួយៗ។
- មន្ត្រីសាលាក្រុងពីនាយកដ្ឋានផ្សេងៗ នឹងនៅឈរតាមបញ្ជរប្រធានបទនីមួយៗ ដើម្បីជួយផ្ដល់ការណែនាំ ស្ដាប់ និងចូលរួមពិភាក្សា។
- មតិដែលប្រមូលបានយប់នេះ និងការស្ទង់មតិអំពីថវិកាផង នឹងត្រូវបញ្ចូលគ្នា និងរាយការណ៍ជូនទៅក្រុមប្រឹក្សាក្រុង នៅរដូវផ្ការីក ដែលជាផ្នែកមួយនៃដំណើរការរៀបចំថវិកា។

# វិន័យក្នុងការពិភាក្សា

- **សូមគោរពគ្នា-** នេះមិនមែនជាវេទិកាដេញដោលគ្នាទេ។ ដូច្នេះរាល់ការផ្តល់មតិ និងគំនិត គឺសុទ្ធតែសំខាន់ទាំងអស់ ដែលត្រូវទទួលបានការគោរព និងពិចារណា។
- **ចំណាយពេលតាមសម្រួល និងផ្តល់ឱកាសឲ្យអ្នកដទៃផង** ដើម្បីឲ្យគ្រប់គ្នាដែលចង់ចូលរួមជាគំនិត បានបញ្ចេញគំនិត។ ពេលបងប្អូនដើរទៅតាមកន្លែងប្រធានបទនីមួយៗ និងពេលនិយាយទៅកាន់មន្ត្រី សូមសម្លឹងមើលក្រែងមានអ្នកឯទៀតចង់និយាយដែរ។
- **និយាយតាងនាមខ្លួនឯង ដោយយោងលើបទពិសោធន៍ផ្ទាល់ខ្លួន** និងចៀសវាងនិយាយជួសគេ ឬនិយាយជំនួសជារួមឲ្យក្រុមណាមួយផ្សេងទៀត។



CITY OF LONG BEACH

# Budget Priority Survey

CITY OF LONGBEACH

## ការស្ទង់មតិរកចំណុចសំខាន់ៗបំផុតសម្រាប់ថវិកាឆ្នាំសារពើពន្ធ ២០២៥ របស់ក្រុងឡុងប៊ិច

ដើម្បីបំពេញការស្ទង់មតិនេះ ទៅតាមភាសាក្រៅពីអង់គ្លេស សូមចុចលើតំណភ្ជាប់ និងរូបនៅផ្នែកជ្រុងខាងស្ដាំលើគេ។ បងប្អូននឹងអាចឃើញភាសាអេស្ប៉ាញ តាហ្គាឡុក និងខ្មែរ។ ការស្ទង់មតិនេះបិទបញ្ចប់នៅត្រឹមថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០២៤ វេលាម៉ោង ៥ល្ងាច។

**www.longbeach.gov/fy25**

ព័ត៌មានបន្ថែមអំពីចក្ខុវិស័យយុទ្ធសាស្ត្រឆ្នាំ ២០៣០៖ www.longbeach.gov/vision2030

Fiscal Year
2025
Proposed
Budget

# កិច្ចប្រជុំសុំយោបល់សហគមន៍រឿងថវិកា

សម្រាប់ព័ត៌មានបន្ថែម សូមមើល៖
**www.longbeach.gov/fy25**

CITY OF
LONG
BEACH

កិច្ចប្រជុំសុំយោបល់សហគមន៍រឿងថវិកា

